# របាយការណ៍ប្រចាំឆមាសទី១ ឆ្នាំ២០១៧ របស់មន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្តាល

## I.សេចក្តីផ្តើម

### ១. ស្ថានភាពភូមិសាស្ត្រ

ខេត្តកណ្តាល មានផ្ទៃដីសរុប ៣,២១១.៧៥៩ ម៉ែត្រក្រឡា ,ចំនួនគ្រួសារសរុប ២៤៩,៩៩១ គ្រួសារ , ចំនួនប្រជាជនសរុប ១,២១៩,៩៩១ នាក់ ស្រីចំនួន ៦១៩,២១២ នាក់ មាន ១០ ស្រុក ០១ក្រុង ១២៧ ឃុំ និង ១០១០ ភូមិ។

### ២. ស្ថានភាពការងាររបស់មន្ទីរ

**ក. មន្ត្រីរាជការសរុប ÷** ៧៨ នាក់ ក្នុងនោះស្រី ២១ នាក់

- ថ្នាក់ខេត្ត ៤៧ នាក់ ( ប្រុស ៣១ នាក់ , ស្រី ១៦ នាក់ )
- ថ្នាក់ស្រុក ៣១ នាក់ (ប្រុស ២៦ នាក់ , ស្រី ០៥ នាក់ )

**ខ. ចំនួនមន្ត្រីរាជការកំពុងសហការជាមួយដៃគូរអង្គការអន្តរជាតិនានា សរុប ១៨ នាក់ ក្នុងនោះ÷**

- សហការជាមួយកម្មវិធី គ.ជ.អ.ប ចំនួន ០២ នាក់
- សហការជាមួយអង្គការយូនីសេហ្វ,មូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារ Unicef (United Nations children's Fund ) ចំនួន ០៧ នាក់
- សហការជាមួយអង្គការកម្ពុជា ដើម្បីកុមារ និងការអភិវឌ្ឍ (COCD (Cambodian Organization for Children ) ចំនួន ០៣ នាក់
- សហការជាមួយអង្គការមូលនិធិសិទ្ធិកុមារ (CRF) ចំនួន ០២ នាក់
- សហការជាមួយអង្គការទស្សនពិភពលោក (World Vision) ចំនួន ០៤ នាក់

**គ. ការងាររដ្ឋបាល÷**

- បញ្ជូនឯកសារបៀវត្សប្រចាំខែមករា កុម្ភៈ មីនា មេសា ឧសភា និងខែមិថុនា ឆ្នាំ២០១៧ ដល់មន្ទីរមុខងារសាធារណៈ រួចរាល់។
- គ្រប់គ្រងបញ្ជីវត្តមានប្រចាំថ្ងៃ ប្រចាំសប្តាហ៍ ប្រចាំខែ ប្រចាំត្រីមាសទី១ ប្រចាំឆមាសទី១ ឆ្នាំ២០១៧ និងរៀបចំរបាយការណ៍ ខែមករា កុម្ភៈ មីនា មេសា ឧសភា និងមិថុនា ឆ្នាំ២០១៧ ផ្ញើទៅក្រសួងទាន់ពេលវេលា ។
- រៀបចំឯកសារស្នើសុំមន្ត្រីក្របខណ្ឌថ្មី និងមន្ត្រីជាប់កិច្ចសន្យា សម្រាប់ឆ្នាំ២០១៨ ជូនក្រសួងអភិវឌ្ឍន៍ជនបទ ។
- បានធ្វើឯកសារដាក់បញ្ញត្តិលោក ឃុន សុផល ចាប់ពីខែមីនា ដល់ខែឧសភា ឆ្នាំ២០១៧ ក្នុងនោះមានទាំងការបង្កកប្រាក់ខែផងដែរ។
- ចូលរួមប្រជុំពិភាក្សារៀបចំពិពណ៌នាមុខតំណែងសម្រាប់មន្ត្រីក្នុងមុខតំណែងសម្រាប់មន្ត្រីរាជការក្នុងតំណែងវិជ្ជាជីវៈ នៅសាលប្រជុំទីស្តីការក្រសួងមុខងារសាធារណៈ។

- ទទួលលិខិតពីក្រសួង និងស្ថាប័ននានា ចំនួន ១៤៨ លេខ។
- បញ្ជូនលិខិតចេញទៅក្រសួង និងស្ថាប័នផ្សេងៗ ចំនួន ១៣៧ លេខ។

**ឃ. ការងារហិរញ្ញវត្ថុ ÷**

- រៀបចំបៀវត្សខែមករា កុម្ភៈ មីនា មេសា ឧសភា និងមិថុនា ឆ្នាំ២០១៧ របស់មន្ត្រីរាជការស៊ីវិល និងមន្ត្រីកិច្ចសន្យាដល់រតនាគារជាតិ។
- ចូលរួមប្រជុំផ្សព្វផ្សាយសារាចរណែនាំការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០១៧ នៅមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុខេត្ត។
- ឆ្លងឯកសារសម្រេចទូទាត់ឆ្នាំ២០១៦ ជាមួយមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- រៀបចំបៀវត្សមន្ត្រីជាប់កិច្ចសន្យាប្រចាំខែមករា និងខែកុម្ភៈ ឆ្នាំ២០១៧ ។
- រៀបចំកម្មវិធីត្រីមាសទី២ ឆ្នាំ២០១៧ ជូនមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- ចូលរួមផ្ទៀងផ្ទាត់ប្រៀបធៀបតារាងសារពើភណ្ឌ ឆ្នាំ២០១៦ នៅមន្ទីរសេដ្ឋកិច្ច-ហិរញ្ញវត្ថុ ខេត្តកណ្តាល។
- ចូលរួមប្រជុំស្តីពីសហគមន៍សន្សំប្រាក់រៀបចំដោយនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ នៅទីស្តីការក្រសួងអភិ ជនបទ។
- ចូលរួមវគ្គបណ្តុះបណ្តាល និងវិក្រិតការ វិធាន និងបទបញ្ញត្តស្តីពីលទ្ធកម្មសាធារណៈជូនក្រុមលទ្ធកម្មនៃអង្គភាព ថវិកាថ្នាក់មូលដ្ឋាននៅសណ្ឋាគារភ្នំពេញ។
- ចូលរួមប្រជុំ និងត្រួតពិនិត្យវាយតម្លៃប្រគល់ទទួលការងារជួសជុលសាងសង់ផ្លូវបេតុងឆ្អឹងដែកចំនួន ០២ ខ្សែ នៅ ស្រុកស្អាង ខេត្តកណ្តាល។
- ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ។

**ង. ការងារផែនការ និងស្ថិតិ ÷**

- រៀបចំរបាយការណ៍ប្រចាំខែមករា កុម្ភៈ មីនា មេសា ឧសភា មិថុនា ប្រចាំត្រីមាសទី១ ប្រចាំឆមាសទី១ ឆ្នាំ ២០១៧ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្តាល ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត សាលាខេត្ត និងក្រសួងអភិវឌ្ឍន៍ជនបទបានទាន់ពេលវេលា។
- ចូលរួមសិក្ខាសាលាឆ្លុះបញ្ចាំងស្តីពីផែនការសុវត្ថិភាពទឹកនៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រៃវែង ដែលមានអ្នកចូលរួម សរុប ១២ នាក់ ស្រី ០២ នាក់។
- រៀបចំធ្វើបច្ចុប្បន្នសៀវភៅផែនការថវិកាឆ្នាំ២០១៧ ជូនមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត និងក្រសួងអភិវឌ្ឍន៍ជនបទបានទាន់ពេលវេលា។
- ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ។

- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការឆ្នាំ២០១៨-២០២០ នៅសាលប្រជុំមន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកណ្តាល ។
- ចូលរួមសិក្ខាសាលាស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០ និងការរៀបចំផែនការថវិកាឆ្នាំ២០១៨ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅមន្ទីរអភិវឌ្ឍន៍ជនបទខេត្តព្រះសីហនុ។
- រៀបចំសៀវភៅផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០១៨-២០២០ និងការរៀបចំផែនការថវិកាឆ្នាំ២០១៨ ផ្ញើជូនសាលាខេត្ត និងក្រសួងបានទាន់ពេលវេលា។

**ច. ផ្លូវជនបទ÷**

- ចុះសិក្សាខ្សែផ្លូវថែទាំខួបឆ្នាំ២០១៧ ចំនួន ០៥ ខ្សែ ២៤,៣៧ គ.ម ក្នុងនោះរួមមាន÷
  - ថែទាំខួបផ្លូវភូមិចន្លក់ក្នុង-ភូមិចន្លក់ក្រៅ ឃុំគគី ស្រុកកៀនស្វាយ ប្រវែង ៥ គ.ម
  - ថែទាំខួបផ្លូវឃុំសំបួរ-ឃុំព្រែកឬស្សី ស្រុកល្វាឯម ប្រវែង ២,៩ គ.ម
  - ថែទាំខួបផ្លូវឃុំរកាជន្លឹង ស្រុកខ្សាច់កណ្តាល ប្រវែង ៨ គ.ម
  - ថែទាំខួបផ្លូវកំពង់ចម្លង ស្រុកខ្សាច់កណ្តាល ប្រវែង ៤,៧ គ.ម
  - ថែទាំខួបផ្លូវឃុំបាក់ដាវ ស្រុកខ្សាច់កណ្តាល ប្រវែង ៣,៧៧ គ.ម
  - ចូលរួមប្រជុំក្នុងការិយាល័យផ្លូវលំស្តីពីការរៀបចំតួនាទី និងភារកិច្ចមន្ត្រីនៅក្នុងការិយាល័យផ្លូវលំ។

. បានលើកគំរោងធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ដើម្បីស្ថាបនាខ្សែផ្លូវក្រាលកៅស៊ូ ចំនួន៣២ ខ្សែ ប្រវែង ១១៧ គ.ម ចំនួន ១០ ស្រុក និងបានបញ្ចូលខ្សែផ្លូវទាំងអស់នៅក្នុងផែនទីដើម្បីដាក់បង្ហាញជូនក្រសួងអភិវឌ្ឍន៍ជនបទ។

. បានចុះសិក្សាខ្សែផ្លូវគំរោងធនាគារពិភពលោក ចំនួន ០៧ ខ្សែ នៅស្រុកអង្គស្នួល ស្រុកកណ្តាលស្ទឹង និងស្រុក ពញាឮ ខេត្តកណ្តាល។

- ចុះសិក្សាខ្សែផ្លូវថែទាំខួប នៅឃុំសំបួរ ស្រុកល្វាឯម ចំនួន ០១ ខ្សែ ប្រវែង ២០០០ ម៉ែត្រ។
- ធ្វើបច្ចុប្បន្នភាពទិន្នន័យផ្លូវជនបទ នៅស្រុកកណ្តាលស្ទឹង ចំនួន ០៨ ខ្សែ ប្រវែង ១០,២១០ ម៉ែត្រ។
- រៀបចំសំណើគម្រោងជួសជុលផ្លូវបន្ទាន់ក្រាលខ្សាច់ភ្នំ ទទឹងខ្នងលើ ០៥ ម៉ែត្រ នៅឃុំបន្ទាយដែក ស្រុកកៀនស្វាយ ចំនួន ០១ ខ្សែ ប្រវែង៣,៥០០ ម៉ែត្រ។
- ចុះវាយតម្លៃប្រគល់-ទទួលគម្រោងផ្លូវបេតុងឆ្អឹងដែក នៅឃុំទឹកវិល និងឃុំព្រែកគយ ចំនួន ០១ ខ្សែ ប្រវែង ១,៨៣៧ ម៉ែត្រ ទទឹង ៤,៥ ម៉ែត្រ។
- ធ្វើបច្ចុប្បន្នភាពផ្លូវប្រភេទ ទី៤ ចំនួន ១០ ខ្សែប្រវែង ២១,៣០០ ម៉ែត្រ នៅក្រុងតាខ្មៅ ខេត្តកណ្តាល។
- ធ្វើបច្ចុប្បន្នភាពខ្សែផ្លូវ ចំនួន ១០ ខ្សែ ប្រវែង ២៧៩៧៥ ម៉ែត្រ ស្ថិតនៅស្រុកមុខកំពូល ខេត្តកណ្តាល។
- ចូលរួមជាមួយក្រុមការងារក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ចុះសិក្សា ខ្សែផ្លូវបន្ទាន់ចំនួន ០១ ខ្សែ ប្រវែង ៥០០០ ម៉ែត្រ ស្ថិតនៅភូមិអង្គជ័យ ឃុំបន្ទាយដែក ស្រុកកៀនស្វាយ ខេត្តកណ្តាល។

- ចូលរួមជាមួយអន្តរក្រសួងរួមមានក្រសួងអភិវឌ្ឍន៍ជនបទ និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុដើម្បីសិក្សាខ្សែផ្លូវត្រូវជួសជុលបន្ទាន់ចំនួន ០១ ខ្សែ ប្រវែង ៣៥០០ ម៉ែត្រ ស្ថិតនៅភូមិជ័យឧត្តម ឃុំសំរោងធំ ស្រុកកៀនស្វាយ ខេត្តកណ្តាល។
- ធ្វើបច្ចុប្បន្នភាពខ្សែផ្លូវ ចំនួន ១០ ខ្សែ ប្រវែង ១៧,៥៧០ ម៉ែត្រ ស្ថិតនៅ ស្រុកល្វាឯម ខេត្តកណ្តាល។

**ឆ. ទឹកស្អាតជនបទ÷**

- ចុះកំណត់ទីតាំងអណ្តូងស្នប់ និងស្រះដែលជាជំនួយឥតសំណងសាធារណរដ្ឋប្រជាមានិតចិន(ជំហ៊ានទី ១) បានចំនួន ១៤២ អណ្តូង ស្រះចំនួន ១១ នៅ ១១៦ ភូមិ,ឃុំចំនួន ២៣ ឃុំ ស្រុក ចំនួន ០៥ ស្រុក (ស្រុកមុខកំពូល,ស្រុកខ្សាច់កណ្តាល,ស្រុកពញាឮ,ស្រុកល្វាឯម ,ស្រុកអង្គស្នួល)ក្នុងនោះរួមមាន÷

  1-ស្រុកមុខកំពូល÷ ០៣ ឃុំ ០៨ ភូមិ មានអណ្តូងស្នប់ចំនួន ១៦ អណ្តូង

  2-ស្រុកខ្សាច់កណ្តាល÷ ០៦ ឃុំ ១៧ ភូមិ មានអណ្តូងស្នប់ចំនួន ២៦ អណ្តូង

  3-ស្រុកពញាឮ÷ ០៦ ឃុំ ៦២ ភូមិ មានអណ្តូងស្នប់ចំនួន ៦២ អណ្តូង ស្រះចំនួន ១០ ស្រះ

  4-ស្រុកល្វាឯម÷ ០៤ ឃុំ ០៨ ភូមិ មានអណ្តូងស្នប់ចំនួន ០៧ អណ្តូង ស្រះចំនួន ០១ ស្រះ

  5-ស្រុកអង្គស្នួល÷ ០៤ ឃុំ ២១ ភូមិ មានអណ្តូងស្នប់ចំនួន ៣១ អណ្តូង។

▪ <u>អនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ គាំទ្រដោយអង្គការយូនីសេហ្វ Unicef (United Nations children's Fund</u> (មូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារ) ÷

- រៀបចំប្រជុំប្រចាំត្រីមាសទី៤ ដើម្បីបូកសរុបលទ្ធផល និងផ្ទៀងផ្ទាត់ស្តីពីការកែលម្អប្រភពទឹកប្រើប្រាស់នៅថ្នាក់ឃុំចំនួន ០១ លើក នៅឃុំសិប្បូរ ស្រុកល្វាឯម ខេត្តកណ្តាល ដែលមានសមាសភាពចូលរួមសរុបចំនួន ១៦ នាក់ ស្រី ០៣ នាក់ ជាលទ្ធផលសម្រេចបានរួមមាន÷
- ស្រះសហគមន៍ចំនួន ០២ ស្រះ បានស្តាររួច នៅភូមិសិប្បូរ និងភូមិព្រែកចារ ឃុំសិប្បូរ ស្រុកល្វាឯម
- អណ្តូងស្នប់បានចាក់សាបរួចចំនួន ១៥ អណ្តូង
- អណ្តូងបានធ្វើរបងរួចចំនួន ០២ អណ្តូង
- បានធ្វើកំណល់ពាង និងទិញគំរបពាង ចំនួន ៩២ គ្រួសារ ស្មើនិង ៩២ ខ្នងផ្ទះ លើខ្នងផ្ទះសុបចំនួន ១២០៣ ខ្នងផ្ទះ។
- ទុកដាក់ទឹកផឹកមានសុវត្ថិភាពចំនួន ១២៣ ខ្នងផ្ទះ។
- អនាម័យបរិស្ថានក្នុងឃុំ ចំនួន ៧0%។
- ចុះរៀបចំប្រជុំប្រចាំត្រីមាសទី១ ឆ្នាំ២០១៧ ដើម្បីបូកសរុបលទ្ធផល និងផ្ទៀងផ្ទាត់ស្តីពីការកែលម្អប្រភពទឹកប្រើប្រាស់នៅឃុំសិប្បូរ ស្រុកល្វាឯម ដែលមានអ្នកចូលរួមសរុប ១៧ នាក់ ស្រី ០២ នាក់។
- រៀបចំប្រជុំតំរង់ទិសស្តីពីផែនការសុវត្ថិភាពទឹក និងរៀបចំក្រុមការងារផែនការសុវត្ថិភាពទឹកថ្នាក់ឃុំ នៅឃុំបឹងគ្រំ ស្រុកល្វាឯម និងឃុំកំពង់ភ្នំ ឃុំព្រែកទន្លាប់ ស្រុកលើកដែក ដែលមានអ្នកចូលរួមសរុប ៤៣ នាក់ ស្រី ១៥ នាក់។

- រៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីការផែនការសុវត្ថិភាពទឹកដល់ក្រុមការងារផែនការសុវត្ថិភាពទឹកថ្នាក់ឃុំ នៅសាលាឃុំបឹងគ្រំ ស្រុកល្វាឯម និងសាលាឃុំកំពង់ភ្នំ- សាលាឃុំព្រែកទន្លាប់ ស្រុកលើកដែក ដែលមានសមាសភាពចូលរួមសរុបចំនួន ៤១ នាក់ ស្រី ០៧ នាក់ ក្នុងនោះមានក្រុមការងារផែនការសុវត្ថិភាពទឹកឃុំបឹងគ្រំ ស្រុកល្វាឯម ចំនួន ១០នាក់ ស្រី ០៣នាក់,ក្រុមការងារផែនការសុវត្ថិភាពទឹកឃុំកំពង់ភ្នំ ស្រុកលើកដែក ចំនួន ១៧ នាក់ ស្រី០១ នាក់,ក្រុមការងារផែនការសុវត្ថិភាពទឹកឃុំព្រែកទន្លាប់ ស្រុកលើកដែក ចំនួន ១៤ នាក់ ស្រី ០៣ នាក់។
- រៀបចំបើកវគ្គបណ្តុះបណ្តាល ស្តីពីការផែនការសុវត្ថិភាពទឹកដល់ក្រុមការងារផែនការសុវត្ថិភាពទឹកថ្នាក់ភូមិចំនួន ១០ ភូមិ នៅសាលាឃុំបឹងគ្រំ ស្រុកល្វាឯម ,សាលាឃុំកំពង់ភ្នំ,សាលាឃុំព្រែកទន្លាប់ ស្រុកលើកដែក ដែលមាន សមាសភាពចូលរួមសរុប ចំនួន ៦៦ នាក់ស្រី២២នាក់ ក្នុងនោះមានក្រុមការងារផែនការសុវត្ថិភាពទឹកភូមិមកពី ឃុំបឹងគ្រំ ស្រុកល្វាឯមចំនួន ១២ នាក់ ស្រី ០២ នាក់,ក្រុមការងារផែនការសុវត្ថិភាពទឹកភូមិមកពីឃុំកំពង់ភ្នំ ស្រុកលើកដែកចំនួន ២៤ នាក់ ស្រី ០៩ នាក់,ក្រុមការងារផែនការសុវត្ថិភាពទឹកភូមិមកពីឃុំព្រែកទន្លាប់ ស្រុក លើកដែក ចំនួន ២៤ នាក់ ស្រី ០៨ នាក់ និងក្រុមប្រឹក្សាឃុំ គ ក ន ក ឃុំ មកពីឃុំទាំងបីចំនួន ០៦ នាក់ ស្រី ០៣ នាក់។

**ជ.អនាម័យជនបទ÷**

ក.អនុវត្តគម្រោងផ្គត់ផ្គង់ទឹកស្អាត និងអនាម័យជនបទ គាំទ្រដោយអង្គការយូនីសេហ្វ Unicef (United Nations children's Fund (មូលនិធិអង្គការសហប្រជាជាតិ ដើម្បីកុមារ) ÷

- ចុះតាមដាន និងត្រួតពិនិត្យការងារអនុវត្តអនាម័យ (CLTs) ០៣ ស្រុក ០៦ ឃុំ ៦៤ ភូមិ នៅស្រុកមុខកំពូល ស្រុកស្អាង និងស្រុកកោះធំ ខេត្តកណ្តាល ជាលទ្ធផលសម្រេចបាន÷
  - បង្គន់សាងសង់ថ្មីចំនួន ៦៥ បង្គន់
  - ចំនួនគ្រួសារទទួលបានការអប់រំចំនួន ១០១៨ គ្រួសារ សមាជិកសរុប ៣១២០ នាក់ ស្រី ២១៧៦ នាក់។
  - គ្រួសារស្ម័គ្រចិត្តសាងសង់បង្គន់ ១១០ គ្រួសារ។
- ចុះផ្ទៀងផ្ទាត់វាយតម្លៃភូមិឃុំដែលត្រូវបានជម្រុញទៅជាភូមិ-ឃុំ បញ្ឈប់បន្ទោបង់ពាសវាលពាសកាល (ODF)ចំនួន ០៨ ភូមិ នៅឃុំទឹកវិល ស្រុកស្អាង។
- ធ្វើពិធីអបអរសាទរភូមិបញ្ឈប់បន្ទោបង់ពាសវាលពាសកាល ODF ចំនួន ១៨ ភូមិ នៅ ០៣ ឃុំ គឺឃុំព្រែកស្តីស្រុកកោះធំ,ឃុំទឹកវិល ឃុំព្រែកអំបិល ស្រុកស្អាង។
- ធ្វើពិធីអបអរសាទរឃុំបញ្ឈប់បន្ទោបង់ពាសវាលពាសកាល ODF ចំនួន ០២ ឃុំ គឺឃុំព្រែកអញ្ចាញ និងឃុំរកាខ្ពស់ ស្រុកស្អាង សរុប ១៤ ភូមិ។
- ចូលរួមប្រជុំឆ្លុះបញ្ចាំងបូកសរុបលទ្ធផលប្រចាំត្រីមាសទី៤ ឆ្នាំ២០១៦ ថ្នាក់ឃុំ ស្តីពីការងារអនុវត្តអនាម័យ (CLTS) នៅឃុំព្រែកស្តី ស្រុកកោះធំ ដែលមានសមាសភាពចូលរួមសរុប ០៨ នាក់ ស្រី ០១ នាក់។

- ប្រជុំផ្សព្វផ្សាយស្តីពីការងារអនុវត្តអនាម័យ )CLTS )ចំនួន ០៣ ឃុំ (ឃុំលំហាច ឃុំសំរោងលើ និង ឃុំម្កាក់
- ស្រុកអង្គស្នួល ដែលមានអ្នកចូលរួមចំនួន ១៦៦ នាក់ ស្រី ៣៧ នាក់។
- ចុះប្រមូលទិន្នន័យដើមគ្រា )PVA ) និងគូសផែនទីភូមិ ចំនួន ៧៧ ភូមិ ០៣ឃុំ (ឃុំសំរោងលើ ឃុំម្កាក់ និងឃុំលំហាច ស្រុកអង្គស្នួល ដែលមានអ្នកចូលរួមសរុប ២៣១ នាក់ ស្រី ៨១ នាក់ ។
- ចុះស្រង់ទិន្នន័យដើមគ្រា និងគូរផែនទីភូមិ ចំនួន ៧៧ ភូមិ ០៣ ឃុំ (លំហាច សំរោងលើ ម្កាក់)ស្រុកអង្គស្នួល។
- ធ្វើពិធីអនាម័យបោសសំអាតភូមិចំនួន ០៩ ភូមិ ០៣ ឃុំ (លំហាច សំរោងលើ ម្កាក់) ស្រុកអង្គស្នួល។
- រៀបចំប្រជុំបូកសរុបលទ្ធផលការងារអនុវត្តអនាម័យថ្នាក់ឃុំ ប្រចាំត្រីមាសទី១ ឆ្នាំ២០១៧ ចំនួន ០៣ ឃុំ (លំហាច  សំរោងលើ ម្កាក់)ស្រុកអង្គស្នួល ដែលមានសមាសភាពចូលរួម ១៧២ នាក់ ស្រី ៣៦ នាក់។
- រៀបចំប្រជុំឆ្លុះបញ្ចាំងបូកសរុបលទ្ធផលប្រចាំត្រីមាសទី១ ឆ្នាំ២០១៧ ថ្នាក់ស្រុក ស្តីពីការងារអនុវត្តអនាម័យ នៅសាលាស្រុកអង្គស្នួល ដែលមានអ្នកចូលរួម ១២ នាក់ ស្រី ០៦ នាក់។

**ឈ. ការអភិវឌ្ឍសហគមន៍ជនបទ ÷**

- រៀបចំធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិ ចំនួន ១៩០ ភូមិ ២១ ឃុំ ក្នុងនោះរួមមាន÷
  1. ឃុំកោះធំ ក ចំនួន ០៧ ភូមិ (ភូមិចុងកោះថ្មី ភូមិក្បាលកោះថ្មី ភូមិពោធិ៍ទន្លេ ភូមិចុងកោះធំ ភូមិកណ្តាលកោះធំ ភូមិក្បាលកោះធំ និងភូមិទួលកន្ទួត)។
  2. ឃុំពោធិបាន ចំនួន ០៩ ភូមិ (ភូមិថ្មី ភូមិព្រៃកតាអ៊ិន ភូមិកំពង់គរ ភូមិព្រៃកតាដុល ភូមិព្រៃកតាវ៉ែន ភូមិពោធិបាន ភូមិព្រៃកម្រេញ ភូមិព្រៃកហង់ និងភូមិក្បាលជ្រោយ)។
  3. ឃុំជ្រោយតាកែវ ចំនួន ០៩ ភូមិ (ភូមិព្រៃកភូមិ ភូមិដើមពោធិ៍ ភូមិព្រៃកតាទៀង ភូមិព្រៃកតាឃិន ភូមិព្រៃកថ្មី   ភូមិព្រៃកតាសេក ភូមិព្រៃកតាឡាច ភូមិកំពង់គរ និងភូមិជ្រោយតាកែវ)។
  4. ឃុំសំពៅពូន ចំនួន ១១ ភូមិ (ភូមិជ្រៃធំ ភូមិព្រៃកស៊ឹង ភូមិកប៉ាល់គៀង ភូមិកោះទៀវ ក ភូមិព្រៃកគង់ ភូមិព្រៃក សែម ភូមិក្បាលកោះទៀវ ភូមិកំពង់ថ្កុល ភូមិខ្ពប ភូមិកោះទៀវ ខ ភូមិព្រៃកស្បូវ)។
  5. ឃុំព្រៃកថ្មី ស្រុកកោះធំ ចំនួន ១២ ភូមិ (ភូមិកំពង់ស្វាយកណ្តាល ភូមិកំពង់ស្វាយក្រោម ភូមិព្រៃកថ្មី ភូមិព្រៃកតាដួង ភូមិចាមលើ ភូមិចាមក្រោម ភូមិព្រៃកតាហ៊ីង ភូមិព្រៃកធន់ ភូមិព្រៃកយាយសាយ ភូមិកំពង់សំបួរលើ ភូមិកំពង់ស្វាយលើ និងភូមិសំបួរក្រោម)។
  6. ឃុំព្រៃកអំបិល ស្រុកស្អាង ចំនួន ១៦ ភូមិពាមប្រជុំ ភូមិព្រៃកអំបិល ភូមិកូនជ្រៃ ភូមិសំប៉ានក្រោម ភូមិអន្លង់ឈើខ្លាង ភូមិឬស្សីដាច់ ភូមិអន្លង់ធំ ភូមិព្រៃកក្រាញ់ ភូមិព្រៃកគ្រួស ភូមិអន្លង់តាសេកក្រោម ភូមិអន្លង់តាសេកលើ ភូមិព្រៃកតាទាវ ភូមិត្រើយត្រឹង្ស ភូមិសំប៉ានលើ ភូមិព្រៃកតាឡៃ និងភូមិព្រៃកថ្មី)។
  7. ឃុំសិត្បូ ស្រុកស្អាង ចំនួន ០៤ ភូមិ (ភូមិព្រៃកតាព្រីង ភូមិសិត្បូ ភូមិកំពង់ព្រីង និងភូមិព្រៃកត្រែង)។

8. ឃុំកោះអន្លង់ចិន ចំនួន ០៤ ភូមិ (ភូមិចុងកោះ ភូមិស្វាយពុំត្រង់ ភូមិកណ្ដាលកោះ និងភូមិក្បាលកោះ) ។
9. ឃុំក្រាំងយ៉ូវ ចំនួន ១៩ ភូមិ(ភូមិតាគល់ ភូមិសំរោង ភូមិអំពិល ភូមិពីងពង់ ភូមិអណ្ដូង ភូមិទួលក្រាំង ភូមិតាពេជ ភូមិអង្គ ភូមិចេក ភូមិគរ ភូមិកណ្ដាល ភូមិធំ ភូមិកំពង់ពោធិ៍ ភូមិវិហារ ភូមិរការ ភូមិទួលក្រូច ភូមិកំពង់ពោធិ៍ត្បូង ភូមិស្វាយដំណាក់ និងភូមិអម្ពឹសលាស់)។
10. ឃុំខ្ពប ចំនួន ១០ ភូមិ (ភូមិត្នោតញី ភូមិព្រៃទទឹង ភូមិដំរីឆ្លង ភូមិបឹងខ្ពប ភូមិកោះថ្មី ភូមិរកាក្រោម ភូមិរកាលើ ភូមិខ្ពបក្រោម ភូមិខ្ពបលើ និងភូមិឬស្សីស្រុក)។
11. ឃុំរកាខ្ពស់ ស្រុកស្អាង មានចំនួន ០៧ ភូមិ (ភូមិកោះត,ភូមិព្រែកថី,ភូមិព្រែកសំរោង,ភូមិព្រែកខ្សេវ, ភូមិទួលក្រសាំង ,ភូមិព្រែកឡុង និងភូមិកោះរំដួល )។
12. ឃុំកោះខ្សាច់ទន្លា ស្រុកស្អាង មានចំនួន ០៨ ភូមិ ( ភូមិក្បាលកោះត្បូង,ភូមិព្រែកយាយម៉ី,ភូមិបទុមសាគរ, ភូមិក្បាលកោះកើត,ភូមិក្បាលកោះលិច,ភូមិកណ្ដាលកោះ,ភូមិចុងកោះកើត និងភូមិចុងកោះលិច )។
13. ឃុំប្រាសាទ ស្រុកស្អាង មានចំនួន ០៥ ភូមិ (ភូមិលេខ ១,ភូមិលេខ២,ភូមិលេខ ៣,ភូមិលេខ៤ និងភូមិលេខ៥)។
14. ឃុំព្រែកគយ ស្រុកស្អាង មានចំនួន ១០ ភូមិ (ភូមិទួលសុភី, ភូមិព្រែកតាជ្រូក, ភូមិស្វាយតានី, ភូមិព្រែកស្មាយភូមិព្រែកស្នង,ភូមិព្រែករុន,ភូមិក្នុងព្រែក,ភូមិព្រែករុនក្រោម,ភូមិត្រពាំងឈូក និងភូមិក្បាលជ្រោយ)។
15. ឃុំត្រើយស្លា ស្រុកស្អាង មានចំនួន ០៩ ភូមិ ( ភូមិពោធិ៍លើ,ភូមិពោធិ៍កណ្ដាល,ភូមិព្រែកតាឯក,ភូមិព្រែកប៉ាន់,ភូមិព្រែកបាឡាត់ឆឹង,ភូមិថ្កុល,ភូមិទួលក្ដី,ភូមិព្រែក និងភូមិពោធិ៍ក្រោម )។
16. ឃុំកោះខែល ស្រុកស្អាង មានចំនួន ០៦ ភូមិ ( ភូមិកោះខែល,ភូមិស្វាយជ្វរ,ភូមិដើមព្រីង,ភូមិទេពអរជូន,ភូមិព្រែកប៉ាង និងភូមិព្រែកកែវ)។
17. ឃុំស្វាយរលំ ស្រុកស្អាង មានចំនួន ០៦ ភូមិ (ភូមិលេខ ១,ភូមិលេខ២,ភូមិលេខ៣,ភូមិលេខ៤,ភូមិលេខ៥ និងភូមិលេខ ១ក )។
18. ឃុំស្អាងភ្នំ ស្រុកស្អាង មានចំនួន ០៩ ភូមិ( ភូមិព្រែកស្ដែង,ភូមិពាមសាលា,ភូមិតាន្ទូ,ភូមិទួលសាលា, ភូមិវាល,ភូមិគោកអណ្ដែត,ភូមិដំរីឆ្លង,ភូមិព្រែកខ្មែរ និងភូមិកំពង់ទ្រា)។
19. ឃុំតាលន់ ស្រុកស្អាង មានចំនួន ០៩ ភូមិ ( ភូមិក្បាលកោះតូច,ភូមិទួលស្ពី,ភូមិព្រែកស្ដែង,ភូមិព្រែកតាឯក,ភូមិវាលត្រែង,ភូមិព្រែកតាប្រាក់,ភូមិតាលន់,ភូមិកណ្ដាលកោះតូច និងភូមិចុងកោះតូច)។
20. ឃុំទឹកវិល ស្រុកស្អាង មានចំនួន ១០ ភូមិ ( ភូមិផ្លូវបំបែក,ភូមិព្រែកពោធិ៍,ភូមិព្រែករាំង,ភូមិព្រែកតាប៊ុម,ភូមិព្រែកថ្មី,ភូមិព្រែកតារ៉ា,ភូមិព្រែកអុងប៉ាង,ភូមិវត្តកណ្ដាល,ភូមិព្រែករាំងក និងភូមិទួលខ្ញូញ ) ។

21. ឃុំស្វាយប្រទាល ស្រុកស្អាង មានចំនួន ០៩ ភូមិ ( ភូមិព្រែកតាសៅ,ភូមិចុងកោះគរ,ភូមិបារ៉ែនលើ, ភូមិអូរចែក,ភូមិបារ៉ែនក្រោម,ភូមិពោធិ៍តាប៉ាង,ភូមិព្រែកតាតិន,ភូមិប្ញស្សីជ្រោយ និងភូមិព្រែកតាជ័រ ) ។

**៣. ការអភិវឌ្ឍសេដ្ឋកិច្ចជនបទ ÷**

- ចូលរួមប្រជុំស្តីពីសហគមន៍សន្សំប្រាក់រៀបចំដោយនាយកដ្ឋានអភិវឌ្ឍន៍សេដ្ឋកិច្ចជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។

**៨. ការងារបណ្តុះបណ្តាល និងស្រាវជ្រាវ÷**

- រៀបចំតារាងរបាយការណ៍មន្ត្រីចូលរួមវគ្គបណ្តុះបណ្តាល និងសិក្ខាសាលា នៅក្នុងរាជធានី-ខេត្ត ចំនួន ០៦ លើក។
- បានធ្វើការផ្សព្វផ្សាយវគ្គបណ្តុះបណ្តាលក្រោមគំនិតផ្តួចផ្តើមសមាហរណកម្មអាស៊ាន ( IAI ) រដ្ឋាភិបាលសឹង្ហបុរី ស្តីពី Basic English Language and Communication Skills (II) ដែលនឹងប្រព្រឹត្តទៅ ពីថ្ងៃ ១៣-៣១ ខែមីនាឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលបណ្តុះបណ្តាលកម្ពុជា-សឹង្ហបុរី ( CSTC) នៅរាជធានីភ្នំពេញ។
- បានធ្វើការជូនដំណឹងដល់មន្ត្រីរាជការមន្ទីរអភិវឌ្ឍន៍ជនបទខេត្ត-ស្រុក ស្តីពីការជ្រើសរើសមន្ត្រីចូលរួមវគ្គសិក្សានៅសាធារណរដ្ឋឥណ្ឌា សម្រាប់ឆ្នាំសិក្សា២០១៦២០១-៧។

**៤. កិច្ចការសាធារណៈ ÷**

- រៀបចំប្រជុំបូកសរុបលទ្ធផលការងារប្រចាំខែមករា កុម្ភៈ មីនា មេសា ឧសភា ខែមិថុនា និងផែនការបន្តឆមាសទី២ ឆ្នាំ២០១៧ ចំនួន ០៦ លើក នៅសាលប្រជុំមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្តាល ដែលមានអ្នកចូលរួមសរុប ចំនួន ៣១ ស្រី ០៥ នាក់។
- ចូលរួមអបអរសាទរព្រះរាជដំណើរដ៏ខ្ពង់ខ្ពស់ របស់ព្រះករុណាជាអង្គម្ចាស់ជីវិតលើត្បូងព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហាក្សត្រី ព្រះវររាជមាតាជាតិខ្មែរជាទីសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ព្រះអង្គព្រះរាជសព្វព្រះហរទ័យស្តេច និងយាងប្រថាប់សម្រាកព្រះកាយ ក្នុងឆ្នាំសកល នៅក្រុងព្រះសីហនុ ខេត្តព្រះសីហនុ នៅឃុំត្រពាំងវែង ស្រុកកណ្តាលស្ទឹង។
- ចូលរួមជាកិត្តិយស ក្នុងពិធីចុះសួរសុខទុក្ខ និងចែកអំណោយដល់អ្នករស់នៅជាមួយមេរោគអេដស៍ស្រុកល្វាឯម ចំនួន ១៧០នាក់ និងស្រុកលើកដែក ចំនួន ១១៩នាក់ នៅវេលាម៉ោង ៨ : ៣០ នាទីព្រឹក ទីតាំងបរិវេណសលាស្រុកល្វាឯម និង វេលាម៉ោង ២ : ៣០ នារសៀល ទីតាំងបរិវេណសាលាស្រុកលើកដែក។
- ចូលរួមពិសារបាយសាមគ្គី អបអរសាទរខួបអនុស្សាវរីយ៍លើកទី ៣៨ ទិវាជ័យជំនះ៧មករា (៧.១.១៩៧៩ ៧.១.២០១៧) នៅសាលាខេត្តកណ្តាល។

- ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីសម្ពោធបើកការដ្ឋានសាងសង់ផ្ទះនៃគម្រោងលំនៅឋានតម្លៃសមរម្យ អនុវត្តដោយក្រុមហ៊ុន Worldbridgeland Co.Ltd នៅភូមិទួលក្រសាំង ឃុំរការខ្ពស់ ស្រុកស្អាង។
- ចូលរួមកិច្ចប្រជុំគណៈអភិបាលខេត្ត នៅសាលប្រជុំ សាលាខេត្ត (អគារ C)។
- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី ៣២ របស់ក្រុមប្រឹក្សាខេត្ត នៅសាលប្រជុំសាលាខេត្ត (អគារ C)។
- ចូលរួមជាភ្ញៀវកិត្តិយសក្នុងពិធីបើក និងបិទ សន្និបាតបូកសរុបការងារ អប់រំ យុវជន និងកីឡាខេត្តកណ្តាលឆ្នាំសិក្សា ២០១៥ ២០១៦ និងលើកទិសដៅឆ្នាំសិក្សា ២០១៦ ២០១៧ នៅមជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគ ហ៊ុនសែន ខេត្តកណ្តាល។
- ចូលរួមផ្សព្វផ្សាយសារាចរណែនាំលេខ ០១៦ សហវ ចុះថ្ងៃទី២៧ ខែធ្នូ ឆ្នាំ២០១៦ ស្តីពីការអនុវត្តច្បាប់ស្តីពីហរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។នៅសាលប្រជុំមន្ទីរសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ខេត្តកណ្តាល។
- ចូលរួមកិច្ចប្រជុំសរុបលទ្ធផលត្រួតពិនិត្យការអនុវត្តច្បាប់ ស្តីពីចរាចរណ៍ផ្លូវគោកឆ្នាំ ២០១៦ និងលើសទិសដៅឆ្នាំ ២០១៧ នៅសាលប្រជុំសាលាខេត្ត (អគារ B)។
- ចូលរួមពិធីសម្ពោធដាក់អោយប្រើប្រាស់ជាផ្លូវការនូវសមិទ្ធផលនានាក្នុងវត្តមជ្ឈឹមសរារាម ស្ថិតនៅភូមិពាម ឃុំរការកោងទី ១ ស្រុកមុខកំពូល។
- ចូលរួមបិទសន្និបាតបូកសរុបការងារឆ្នាំ ២០១៦ និងលើកទិសដៅការងារឆ្នាំ ២០១៧ របស់មន្ទីរអប់រំខេត្ត ។
- ចូលរួមពិធីប្រកាសផ្ទេរភារៈកិច្ច និងតែងតាំងមុខតំណែងអភិបាលរងនៃគណៈអភិបាលខេត្តកណ្តាល នៅសាលាខេត្តកណ្តាល (អគារ B )។
- ចូលរួមជាភ្ញៀវកិត្តិយស ក្នុងពិធីប្រារព្ធទិវាដីសើមពិភពលោកថ្ងៃទី ០២ កុម្ភៈ ឆ្នាំ ២០១៧ នៅចំណុច វត្តស្វាយអណ្តែត ភូមិតាស្គរ ឃុំសារិកាកែវ ស្រុកល្វាឯម ខេត្តកណ្តាល។
- ចុះពិនិត្យ និងវាយតំលៃការស្នើសុំចុះបញ្ជីដីធ្លីតាមលក្ខណៈដាច់ដោយដុំចំនួន ០២ ទីតាំង÷
- ១-នៅភូមិទួលសាលា ភូមិវាល ភូមិគោកសណ្តែក ឃុំស្អាងភ្នំ និងភូមិទួលក្រាំង ភូមិសំរោង ភូមិអំពិលភូមិអំពិលលាស់ និងភូមិតាគល់ ឃុំក្រាំងយ៉ូវ ស្រុកស្អាង សរុបទំហំ ៦៧៥.៤៨៦ហិកតា។
- ២-ស្ថិតនៅភូមិវាល ភូមិទួលសាលា ឃុំស្អាងភ្នំ សរុបទំហំ ១៥២.៨២ហិកតា។
- ចូលរួមសិក្ខាសិលាពិគ្រោះយោបល់និងចែករំលែកបទពិសោធន៍លើកទី២ របស់គម្រោងគ្រប់គ្រងគ្រោះមហន្តរាយ នៅកម្ពុជា និងអាស៊ីអាគ្នេយ៍ នៅសាលប្រជុំជាន់ទី ៣ ទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ ។
- ចូលរួមប្រជុំផ្សព្វផ្សាយស្តីពីការរៀបចំពិព័ណ៌មុខតំណែងសម្រាប់មន្ត្រីរាជការក្នុងរចនាសម្ព័ន្ធរបស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។
- ចូលរួមពិភាក្សាគាំទ្រ និងបន្តកិច្ចសហប្រតិបត្តិការលើគម្រោងនានារបស់អង្គការទស្សនៈពិភពលោក នៅសាលប្រជុំសាលាខេត្តកណ្តាល (អគារ A) ។

- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី ៣៣ របស់ក្រុមប្រឹក្សា នៅសាលប្រជុំសាលាខេត្ត អគារ C ។
- ចូលរួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និង ទិសដៅការងារឆ្នាំ២០១៧ របស់មន្ទីររៀបចំដែនដី នគរូបនីយកម្មសំណង់ និងសុរិយោយដីខេត្តកណ្តាល នៅសាលប្រជុំសាលាខេត្ត អគារ B ។
- ចូលរួមទិវាបង្ការ និងពន្លត់អគ្គីភ័យ នៅសួនច្បារទន្លេបាសាក់ ក្រុងតាខ្មៅ។
- ចូលរួមប្រជុំរៀបចំពិធីអបអរសាទរខួបលើកទី ១០៦ ទិវាសិទ្ធនារី ៨ មីនា ឆ្នាំ២០១៧ នៅសាលប្រជុំសាលាខេត្ត អគារ C។
- ចូលរួមកិច្ចប្រជុំគណៈអភិបាលខេត្ត នៅសាលប្រជុំសាលាខេត្តអគារ C។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាជនក្រីក្រ និងពិធីបញ្ចុះបឋមសីលាសាងសង់អគាររដ្ឋបាលមជ្ឈមណ្ឌលទទួលថែទាំ និងព្យាបាលជនជនវិកលចរិក នៅមជ្ឈមណ្ឌលបុរីកុមារមិត្តភាព កម្ពុជា បារាំង ហុងគ្រី។
- ចូលរួមមីទ្ទីងអបអរសាទរទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី ១១ ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគ ហ៊ុន សែន កណ្តាល។
- ប្រធាន និងអនុប្រធានមន្ទីរ ប្រធាន អនុប្រធានការិយាល័យ និងមន្ត្រីមន្ទីរអភិវឌ្ឍន៍ជនបទខេត្តកណ្តាលបានចូល រួមសន្និបាតបូកសរុបលទ្ធផលការងារឆ្នាំ២០១៦ និងទិសដៅការងារឆ្នាំ២០១៧ របស់ក្រសួងអភិវឌ្ឍន៍ជនបទ នៅសាលសន្និសីទចតុមុខ រាជធានីភ្នំពេញ។
- ចូលរួមមីទ្ទីងអបអរសាទរទិវាវប្បធម៌ជាតិ ០៣ មីនា លើកទី ១៩ ឆ្នាំ២០១៧ នៅមជ្ឈមណ្ឌលគរុកោសល្យ ភូមិភាគ ហ៊ុន សែន កណ្តាល ។
- ចូលរួមប្រជុំសាមញ្ញលើកទី ៣៤ របស់ក្រុមប្រឹក្សាខេត្ត នៅសាលប្រជុំសាលាខេត្ត អាគារ C ។
- ចូលរួមជាកិត្តិយសក្នុងពិធីប្រកាស ផ្ទេរ និងកាន់មុខតំណែងព្រះរាជអាជ្ញានៃអយ្យការអមសាលាដំបូងខេត្តកណ្តាល នៅសាលាខេត្តកណ្តាល អគារ B។
- ចូលរួមជាកិត្តិយសក្នុងពិធីបើកវគ្គបណ្តុះបណ្តាលគណៈកម្មាធិការរដ្ឋបាល ស្តីពីតួនាទីក្នុងការចុះបញ្ជីដីធ្លីមាន លក្ខណៈជាប្រព័ន្ធ នៅសង្កាត់តាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋក្នុងឃុំ សំរោងធំ ស្រុកកៀនស្វាយ។
- ចូលរួមកិច្ចប្រជុំស្តីពីការត្រួតពិនិត្យ និងវាយតំលៃបញ្ចប់លើការអនុវត្តគម្រោងអភិវឌ្ឍន៍ឆ្នាំ២០១៦ រាជធានីខេត្ត។
- ចូលរួមពិធីឆ្លងសមិទ្ធផលនានាក្នុងវត្តគគីរធំ នៅឃុំគគីរធំ ស្រុកកៀនស្វាយ។
- ចូលរួមប្រជុំត្រួតពិនិត្យ និងរៀបចំខ្លឹមសារចងសម្ព័ន្ធមេត្រីភាពជាមួយខេត្ត ប៊ិន យឿន នៃសាធារណៈរដ្ឋសង្គម និយមវៀតណាម នៅសាលប្រជុំសាលាខេត្ត C។
- ចូលរួមក្នុងពីធីគោរពវិញ្ញាណក្ខ័ន្ធសពសម្តេច វិបុលបញ្ញា សុខ អាន សមាជិករដ្ឋសភា និងឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ។

- ចូលរួមកិច្ចប្រជុំវិសាមញ្ញគណៈអភិបាលខេត្ត នៅសាលាខេត្តកណ្តាល (អាគារ C)។
- ចូលរួមជាកិត្តិយសក្នុងពិធីប្រកាស ផ្ទេរ និងកាន់មុខតំណែង ប្រធានមន្ទីរវប្បធម៌ និងវិចិត្រសិល្បៈនៅសាលាខេត្តកណ្តាល (អគារ B)។
- ចូលរួមពិធីសម្ពោធសមិទ្ធផលនានា នៅវត្តជ្រៃមាសសាគរ នៅស្រុកមុខកំពូល ។
- ចូលរួមជាកិត្តិយសក្នុងការបិទផ្សាយជាសាធារណៈនូវឯកសារនៃការវិនិច្ឆ័យចំនួន ១២ ភូមិ នៅវត្តជ័យមង្គលស្រុក កៀនស្វាយ។
- ចូលរួមសន្និបាតបូកសរុបសមិទ្ធផលការងាររបស់ក្រុមប្រឹក្សាឃុំ-សង្កាត់ អាណត្តិទី៣ នៅសាលាខេត្តកណ្តាល អគារ B។
- ចូលរួមសម្របសម្រួលវគ្គបំប៉ន ស្តីពីផែនការសុវត្ថិភាពទឹក និង ពិនិត្យគុណភាពទឹកជាក់ស្តែង ។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋ ឃុំព្រែកគយ ស្រុកស្អាង ។
- ចូលរួមពីធសម្ពោធសមិទ្ធផលនានា នៅវត្តព្រែកអំពិល ស្រុកស្អាង ។
- ចូលរួមពីធសម្ពោធកាត់ខ្សែបូ សាលាធម្មសភា នៅវត្តសិត្បូ ស្រុកស្អាង ។
- ចូលរួមពីធីសម្ពោធអាគាររដ្ឋបាលសាលាស្រុកអង្គស្នួល ។
- ចូលរួមកិច្ចប្រជុំត្រីមាសទី០១ របស់គ.ក.ស.ក ខេត្ត នៅសាលប្រជុំក្រុមប្រឹក្សាខេត្ត ។
- ចូលរួមពីធសម្ពោធសមិទ្ធផលនានា នៅវត្តកំពង់ស្វាយ នៅស្រុកកៀនស្វាយ ។
- ចូលរួមពីធសម្ពោធសមិទ្ធផលនានា នៅវត្តព្រែកហូ ក្រុងតាខ្មៅ ។
- ចូលរួមពីធសម្ពោធសមិទ្ធផលនានា នៅវត្តជ្រោយ ស្រុកកោះធំ ។
- ចូលរួមខួបលើកទី១០ ទិវាយុទ្ធជនកម្ពុជា ២១ មិថុនា ឆ្នាំ២០១៧ នៅសាលាស្រុកមុខកំពូល។
- ចូលរួមពិធីបើកការដ្ឋានផ្លូវបេតុងប្រវែង ១០៣៣ ម៉ែត្រ នៅភូមិព្រែកសំរោង សង្កាត់តាខ្មៅ ក្រុងតាខ្មៅ។
- ចូលរួមពិធីបើកការដ្ឋានផ្លូវបេតុងប្រវែង ៤៥០០ ម៉ែត្រ នៅមុខវិទ្យាល័យទឹកឃ្លាំង ឃុំទឹកឃ្លាំង ស្រុកល្វាឯម។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ១១២៤គ្រួសារ នៅទីស្នាក់ការភូមិកាត់ សង្កាត់តាក្តុល ក្រុងតាខ្មៅ។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន៩៦០គ្រួសារ នៅទីស្នាក់ការសង្កាត់តាខ្មៅ ក្រុងតាខ្មៅ។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៦៨០ គ្រួសារ នៅទីស្នាក់ការសង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៧៧៥ គ្រួសារ នៅដីឡូតិ៍ភូមិព្រែកឫស្សី សង្កាត់ព្រែកឫស្សី ក្រុងតាខ្មៅ ។

- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៧៩៧ គ្រួសារ នៅផ្ទះ ទីវ ប៊ូ សង្កាត់ដើមមៀន ក្រុងតាខ្មៅ។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៩១៣ គ្រួសារ នៅភូមិព្រែកហូរលិច សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ។
- ចូលរួមកិច្ចប្រជុំត្រៀមរៀបចំមីទ្ទីងអបអរសាទរខួបទី ១៥៤ ទីវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា ឆ្នាំ២០១៧ (អគារ C)។
- ចូលរួមជាកិត្តិយសក្នុងពីធី បើក និង បិទ ការប្រកួតការប្រណាំងទូកកាន្ទ (ពានរង្វាន់សម្តេចក្រឡាហោម ស ខេង លើកទី៤ ឆ្នាំ២០១៧ នៅវេទិការប្រណាំងទូក មាត់ទន្លេបាសាក់ សង្កាត់តាខ្មៅ ក្រុងតាខ្មៅ។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៧៣៧ គ្រួសារ នៅទីស្នាក់ការសង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៧៣៨ គ្រួសារ នៅដីឡូតិ៍ភូមិក្រពើហា សង្កាត់ព្រែកឬស្សី ក្រុងតាខ្មៅ។
- ចូលរួមបើកការដ្ឋានផ្លូវបេតុងប្រវែង ១៥៥៤ ម៉ែត្រ នៅផ្លូវមុខវត្តព្រែកហូរ សង្កាត់ព្រែកហូរ ក្រុងតាខ្មៅ។
- ចូលរួមកិច្ចប្រជុំអនុគណៈកម្មាធិការព្រំដែនខេត្តកណ្តាល នៅសាលប្រជុំសាលាខេត្តកណ្តាល (អគារ A)។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៥៨៨ គ្រួសារ នៅស្នាក់ការ គ.១១ សង្កាត់ដើមមៀន ក្រុងតាខ្មៅ។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៨៩២ គ្រួសារ នៅស្នាក់ការសង្កាត់តាខ្មៅ ក្រុងតាខ្មៅ។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៨១២ គ្រួសារ នៅផ្ទះប៊ុត តុក ភូមិព្រែករាំង១ សង្កាត់ កំពង់សំណាញ់ ក្រុងតាខ្មៅ។
- ចូលរួមកិច្ចប្រជុំលើកដំបូងនៃដំណើរការអភិវឌ្ឍន៍គម្រោងសាច់ប្រាក់ពលកម្មសំរាប់ហេដ្ឋារចនាសម្ព័ន្ធជនបទ និង ការគាំទ្រកសិករ នៅទីស្តីការក្រសួងអភិវឌ្ឍន៍ជនបទ។
- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី៣៥ របស់ក្រុមប្រឹក្សាខេត្ត នៅសាសប្រជុំសាលាខេត្ត (អគារ C)។
- ចូលរួមពិធីសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៤ ភូមិ នៅសាលាឃុំសំរោងធំ ស្រុកកៀនស្វាយ។
- ចូលរួមពីធីរំលឹកខួបអនុស្សាវរីយ៍លើកទី ១៣១ នៃទិវាពលកម្មអន្តរជាតិទី១ ខែឧសភា ឆ្នាំ២០១៧ នៅសាលប្រជុំសាលាខេត្ត (អគារ B)។
- ចូលរួមពីធីប្រកាសផ្ទេរភារកិច្ចប្រធានសាខាពន្ធដាខេត្ត នៅសាលប្រជុំសាលាខេត្ត (អគារ B )។

- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយសារាចរណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិការឆ្នាំ២០១៨-២០២០ នៅសាល ប្រជុំ មន្ទីរសេដ្ឋកិច្ចនិងហិរញ្ញវត្ថុខេត្តកណ្តាល។
- ចូលរួមជាកិត្តិយសក្នុងពិធីប្រជុំផ្សព្វផ្សាយសេចក្តីប្រកាសកំនត់តំបន់ធ្វើរការវិនិច្ឆ័យសំរាប់ការចុះបញ្ជីដីធ្លីមានលក្ខណៈជាប្រព័ន្ធ នៅសាលាសង្កាត់តាក្តុល ភូមិតាក្តុល ក្រុងតាខ្មៅ ខេត្តកណ្តាល។
- ចូលរួមមីទ្ទីងអបអរសាទរខួបទី ១៥៤ ទីវាពិភពលោកកាកបាទក្រហម អឌ្ឍចន្ទក្រហម ៨ ឧសភា នៅទីស្នាក់ការសាខាកាកបាទក្រហមកម្ពុជា ខេត្តកណ្តាល ។
- ចូលរួមជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៨១៤ គ្រួសារ នៅទីស្នាក់ការគណៈបក្សខេត្ត(គ.១១) ក្រុងតាខ្មៅ។
- ចូលរួមបុណ្យវិសាខបូជាឆ្នាំរកា នព្វស័ក ព.ស ២៥៦១ គ.ស ២០១៧ នៅសាលាបុណ្យសម្តេចឪ ភ្នំព្រះរាជ្យទ្រព្យ ស្រុកពញាឮ។
- ចូលរួមព្រះរាជពិធីបុណ្យចម្រើនព្រះជន្ម ព្រះករុណា ព្រះបាទសម្តេច ព្រះបរមនាថ នរោត្តមសីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ក្នុងគម្រប់ព្រះជន្ម ៦៤ យាងចូល ៦៥ ព្រះវស្សា នៅសាលាខេត្តកណ្តាល។
- ចូលរួមបើកការដ្ឋានដាក់លូប្រវែង ៨៦៣ ម៉ែត្រ ក្នុងភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ។
- ចូលរួមជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៧៥៩ គ្រួសារ នៅសង្កាត់តាខ្មៅ។
- ចូលរួមជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ៦៥៧ គ្រួសារ នៅសង្កាត់តាខ្មៅ។
- ចូលរួមជួបសំណេះសំណាលជាមួយប្រជាពលរដ្ឋចំនួន ០៤ ភូមិ នៅសាលាបឋមសិក្សាព្រៃទទឹង ឃុំខ្ពបស្រុកស្អាង។
- ចូលរួមកិច្ចប្រជុំគណៈអភិបាលខេត្ត នៅសាលប្រជុំសាលាខេត្ត(អគារC)។
- ចូលរួមក្នុងពិធីសម្ពោធសាលាឃុំប្រាសាទ និងបើកការដ្ឋានស្ថាបនាផ្លូវបេតុង ១,០០០ មែត្រ នៅវត្តប្រាសាទ ឃុំប្រាសាទ ស្រុកស្អាង ខេត្តកណ្តាល។
- ចូលរួមកិច្ចប្រជុំសាមញ្ញលើកទី ៣៦ របស់ក្រុមប្រឹក្សាខេត្ត នៅសាលប្រជុំសាលាខេត្ត( អគារ C )។
- ចូលរួមកិច្ចប្រជុំផ្សព្វផ្សាយកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដំណាក់កាលទី៣ នៅសាលប្រជុំសាលាខេត្ត ( អគារ B )។
- ចូលរួមពិធីបើកការដ្ឋានស្ថាបនាផ្លូវបេតុងប្រវែង ១,០០០ ម៉ែត្រ ទទឹង ៥ ម៉ែត្រ នៅភូមិស្វាយតានី ឃុំព្រែកគយ ស្រុកស្អាង នៅចម្ងាយ ២០០ ម៉ែត្រ ពីក្លោងទ្វារវត្តធនមុនចូលទៅក្នុងនៅក្រោយសាលារៀនស្វាយតានី ភូមិស្វាយតានី ឃុំព្រែកគយ ស្រុកស្អាង។
- ចូលរួមពិធីបើកការដ្ឋានស្ថាបនាផ្លូវបេតុងប្រវែង ១,២៥០ ម៉ែត្រ និងសម្ពោធផ្លូវបេតុង ប្រវែង ១,១០០ ម៉ែត្រនៅឃុំតាលន់ ស្រុកស្អាង នៅមណ្ឌលសុខភាពឃុំតាលន់ ស្រុកស្អាង។

- ចូលរួមពិធីបើកការដ្ឋានស្ថាបនាផ្លូវចាក់កៅស៊ូ DBST ប្រវែង ២,៣០០ ម៉ែត្រ ផ្លូវ ២០១ សង្កាត់កំពង់សំណាញ់ និងសង្កាត់តាខ្មៅ ក្រុងតាខ្មៅ នៅភូមិកំពង់សំណាញ់ សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ (ចូលតាមផ្លូវកៀនបញ្ជាការដ្ឋានកងរាជអាវុធហត្ថខេត្ត)។
- ចូលរួមពិធីបើកការដ្ឋានផ្លូវបេតុងប្រវែង ១,០២០ ម៉ែត្រ និងដាក់លូ ០៣ កន្លែង នៅឃុំកណ្តោក ស្រុកកណ្តាលស្ទឹង នៅផ្ទះភូមិទឹកនឹម ឃុំកណ្តោក ស្រុកកណ្តាលស្ទឹង ប្រឡាយ (ភូមិឆ្នោត)។
- ចូលរួមពិធីបើកការដ្ឋានស្ថាបនាផ្លូវបេឡេប្រវែង ១៥ ម៉ែត្រ គុណ ៤ម៉ែត្រ នៅឃុំគគីរធំ ស្រុកកៀនស្វាយ នៅភូមិគគីរធំ ឃុំគគីរធំ ស្រុកកៀនស្វាយ (កន្ទុយព្រែកថ្មី)។
- ចូលរួមពិធីបើកការដ្ឋានផ្លូវបេតុងប្រវែង ៤៧៧ ម៉ែត្រ និងដាក់លូ ៤៣៤ ម៉ែត្រ នៅភូមិព្រែកតាពៅ សង្កាត់ដើមមៀន ក្រុងតាខ្មៅ នៅភូមិព្រែកតាពៅ១ សង្កាត់ដើមមៀន ក្រុងតាខ្មៅ (វិហារឥស្លាម)។
- ចូលរួមពិធីបើកការដ្ឋានផ្លូវបេតុងនៅឃុំកំពង់អុស ប្រវែង ១,០០០ ម៉ែត្រ និងសម្ពោធសាលាឃុំពញាឮ ស្រុកពញាឮ។
- ចូលរួមពិធីបើកការដ្ឋានផ្លូវបេតុងប្រវែង ៩៧៩ម៉ែត្រ នៅភូមព្រែកំរាង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ នៅភូមិបឹងរាំង សង្កាត់កំពង់សំណាញ់ ក្រុងតាខ្មៅ (ជិតសត្វឃាតដ្ឋាន ព្រែករាំង)។
- ចូលរួម ពិធីសម្ពោធសាលាឃុំបែកចាន និងការដ្ឋាន ស្ថាបនាផ្លូវបេតុង ២២៥ម៉ែត្រ (មុខសាលាឃុំ)ផ្លូវក្នុងផ្សារ ៥០ ម៉ែត្រ និងដាក់លូជ្រុង ប្រវែង ១២៥ ម៉ែត្រ។
- ចូលរួមបើកការដ្ឋានសាងសង់ផ្លូវបេតុងប្រវែង ៤០០ម៉ែត្រ និងដាក់លូ ០១កន្លែង នៅឃុំក្រាំងម្កាក់ ស្រុកអង្គស្នួល ។
- ចូលរួមពិធីសម្ពោធសាលាឃុំដំណាកអំពិល ស្រុកអង្គស្នួល នៅសាលាឃុំដំណាក់អំពិល។
- បានចូលរួមពិធីបើកការដ្ឋានសាងសង់អគារការិយាល័យច្រកចេញចូលតែមួយ ស្រុកស្អាង នៅអគារច្រកចេញចូលតែមួយ ស្រុកស្អាង។
- ចូលរួមពិធីបើកជាផ្លូវការសន្និសីទអន្តរជាតិស្តីពីទេសចរណ៍ប្រកបដោយនិរន្តរភាព និងទីក្រុងបេតិកភ័ណ្ឌលើកទី ១ និងកិច្ចប្រជុំថ្នាក់រដ្ឋមន្ត្រីទេសចរណ៍នៃកិច្ចសន្ទនាសហប្រតិបត្តិការអាស៊ីលើកទី២ ក្រោមអធិបតីដ៏ខ្ពង់ខ្ពស់បំផុត សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាសៀម រាបរីហ្សត ខេត្តសៀមរាប។

**ឍ. យេនឌ័រ÷**

- ចូលរួមក្នុងកិច្ចប្រជុំ គ.ក.ស.ក ខេត្ត ចំនួន ០៦ លើក ក្រោមអធិបតីភាព លោកជំទាវ នួន នារតី នៅសាលប្រជុំ លេខាធិការដ្ឋានក្រុមប្រឹក្សាខេត្ត។
- លោកអនុប្រធានមន្ទីរអភិវឌ្ឍន៍ជនបទ និងមន្ត្រីរាជការជាស្ត្រី ចំនួន ១៦ រូប បានចូលរួមមីទ្ទីញអបអរទរខួបលើក ១០៦ ទិវាអន្តជាតិនារី ០៨ មីនា ឆ្នាំ២០១៧ នៅសាលាខេត្តកណ្តាល។

**II. ទិសដៅការងារសម្រាប់ឆមាសទី ២ ឆ្នាំ២០១៧**

| ល.រ | សកម្មភាពអាទិភាព | ប្រចាំខែ | | | | | |
|---|---|---|---|---|---|---|---|
| | | 7 | 8 | 9 | 10 | 11 | 12 |
| 1 | ធ្វើបច្ចុប្បន្នភាពគណៈកម្មាធិការអភិវឌ្ឍន៍ភូមិចំនួន ១៨០ ភូមិ ២៥ ឃុំ ០២ ស្រុក | √ | √ | √ | √ | √ | √ |
| 2 | ជួសជុលថែទាំផ្លូវខ្វប និងប្រចាំ | √ | √ | √ | √ | √ | √ |
| 3 | ស្តារស្រះ ជួសជុល និងជីកអណ្តូងស្នប់ | √ | √ | √ | √ | √ | √ |
| 4 | គូសផែនទីឃុំ និងភូមិ ស្តីពីផែនការសុវត្ថិភាពទឹកជនបទនៅឃុំបឹងគ្រំ ស្រុកល្វាឯម ឃុំកំពង់ភ្នំ ឃុំព្រែកទន្លាប់ ស្រុកលើកដែក។ | √ | | | | | |
| 5 | សិក្សាគ្រោះថ្នាក់ និងរៀបចំផែនការកែលម្អផែនការសុវត្ថិភាពទឹកនៅនៅឃុំបឹងគ្រំ ស្រុកល្វាឯម ឃុំកំពង់ភ្នំ ឃុំព្រែកទន្លាប់ ស្រុកលើកដែក។ | | √ | √ | √ | | |
| 6 | ត្រួតពិនិត្យផែនការកែលម្អប្រភពទឹកប្រើប្រាស់នៅនៅឃុំបឹងគ្រំ ស្រុកល្វាឯម ឃុំកំពង់ភ្នំ ឃុំព្រែកទន្លាប់ ស្រុកលើកដែក។ | | | | √ | √ | √ |
| 7 | ប្រជុំប្រចាំត្រីមាសទី៣ និងទី៤ ស្តីពីផែនការសុវត្ថិភាពទឹកជនបទ នៅឃុំបឹងគ្រំ ស្រុកល្វាឯម ឃុំកំពង់ភ្នំ ឃុំព្រែកទន្លាប់ ស្រុកលើកដែក។ | | | √ | | | √ |
| 8 | ចុះអនុវត្តការងារអនាម័យទាំងស្រុង (CLTs) នៅស្រុកអង្គស្នួល ០៣ ឃុំ (ឃុំលំហាច ឃុំម្កាក់ និងឃុំសំរោងលើ)ចំនួន ៧៧ ភូមិ។ | √ | √ | √ | √ | √ | √ |

## III. **សេចក្តីសន្និដ្ឋាន**

ដោយមានការយកចិត្តទុកដាក់ខ្ពស់ក្នុងការដឹកនាំ និងណែនាំរបស់ក្រសួងអភិវឌ្ឍន៍ជនបទ អាជ្ញាធរខេត្ត និងដោយមានកិច្ចសហការ និងការគាំទ្រពីអង្គការជាតិ អន្តរជាតិ សប្បុរសជន អាជ្ញាធរគ្រប់លំដាប់ថ្នាក់ ពិសេសការចូលរួមរបស់ប្រជាពលរដ្ឋនៅមូលដ្ឋាន ធ្វើអោយតំបន់ជនបទ ខេត្តកណ្តាល មានការរីកចំរើនគួរអោយកត់សំគាល់លើគ្រប់វិស័យ ពិសេសកំរិតជីវភាពប្រជាពលរដ្ឋត្រូវបានលើកកម្ពស់រួមចំណែកយ៉ាងសំខាន់ដល់ការកាត់បន្ថយភាពក្រីក្រនៅតាមជនបទ និងការអនុវត្តយុទ្ធសាស្ត្រចតុកោណរបស់រាជរដ្ឋាភិបាល។